**សម្តេចពិជ័យសេនា ទៀ បាញ់**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**ផ្ញើជូន**

ឯកឧត្តម នាយឧត្តមសេនីយ៍កិត្តិបណ្ឌិត ហ៊ីង ប៊ុនហៀង អគ្គមេបញ្ជាការរង
និងជាមេបញ្ជាការ បញ្ជាការដ្ឋានអង្គរក្ស និងលោកជំទាវ

*ឯកឧត្តម លោកជំទាវ ជាទីរាប់អាន,*

ភរិយាខ្ញុំ និងរូបខ្ញុំ បានទទួលដំណឹងដ៏ក្រៀមក្រំអំពីមហាឧបាសិកា **តាត់ ឡឹម** ដែលត្រូវជាម្តាយបង្កើត និងម្តាយក្មេក របស់ឯកឧត្តម និងលោកជំទាវ បានទទួលមរណភាព នៅវេលាម៉ោង១៤:៤៥នាទី ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ ក្នុងជន្មាយុ៨៨ឆ្នាំ ដោយជរាពាធ ។

មរណភាពរបស់មហាឧបាសិកា **តាត់ ឡឹម** គឺជាការបាត់បង់មាតា ជីដូន ប្រកបដោយព្រហ្មវិហារធម៌ ដែលមានទឹកចិត្តស្រឡាញ់កូនបំផុតអស់ពីចិត្តពីថ្លើម ហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីកូនចៅ និងជាការបាត់បង់កុលធីតាខ្មែរមួយរូប ធ្លាប់មានស្នាដៃនិងគុណបំណាច់ដ៏ធំធេង ដែលបានចូលរួមចំណែកក្នុងការងារមនុស្សធម៌ និងកិច្ចការសង្គម ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ ព្រមទាំងជាឧបាសិកា គឺជាពុទ្ធសាសនិកមួយរូប ដែលបានរួមចំណែកយ៉ាងសំខាន់ដល់វិស័យព្រះពុទ្ធសាសនានៅកម្ពុជា ។

ក្នុងឱកាស មានទុក្ខដ៏ក្រៀមក្រំនេះ ភរិយាខ្ញុំ និងរូបខ្ញុំ សូមចូលរួមរំលែកទុក្ខនូវមរណទុក្ខដោយក្តីស្រណោះ និងការអាឡោះអាល័យជាមួយឯកឧត្តម លោកជំទាវ និងបុត្រា បុត្រី ព្រមទាំងបងប្អូនកូនចៅទាំងអស់នៃសព ដោយសេចក្តីសង្វេគជាទីបំផុត ។

ភរិយាខ្ញុំ និងរូបខ្ញុំ សូមឧទ្ទិសបួងសួងឲ្យដួងវិញ្ញាណក្ខន្ធមហាឧបាសិកា **តាត់ ឡឹម** បានចាប់កំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិៗ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមឯកឧត្តម និងលោកជំទាវ ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨

**ទៀ បាញ់**